**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ១៦ **អយក.** ៨៣៥

# សេចក្ដីណែនាំ
# ស្ដីពី
# ការអនុវត្តវិធានអប់រំផ្សព្វផ្សាយ ដើម្បីបង្ការការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅតាមគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជន

ក្នុងគោលបំណងអនុវត្តវិធានការនៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមស្មារតីនៃសេចក្ដីសម្រេចលេខ០៨ សសរ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតគណៈកម្មការចម្រុះប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបដល់លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត ត្រូវធ្វើការណែនាំជាបន្ទាន់ដល់គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ឱ្យចូលរួមអនុវត្តនូវសកម្មភាពដូចខាងក្រោម ៖

- រៀបចំផែនការ និងកាលវិភាគបង្រៀនឱ្យបានច្បាស់លាស់អំពីគ្រឿងញៀន ក្នុងនោះរួមមាន ៖ អ្វីទៅជាគ្រឿងញៀនខុសច្បាប់ ការប៉ះពាល់សុខភាព ប៉ះពាល់សុភមង្គល និងជីវភាពរស់នៅបុគ្គល និងគ្រួសារ ប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម និងអាចគ្រោះថ្នាក់ដល់អាយុជីវិតទៀតផង។ ក្នុងកិច្ចដំណើរការបង្រៀននេះត្រូវអនុវត្តឱ្យបានយ៉ាងតិចមួយម៉ោងក្នុងមួយសប្ដាហ៍
- ធ្វើការអប់រំបន្ថែមនៅពេលសិស្សប្រមូលផ្ដុំ ឬពេលវេលាសមស្របណាមួយ ដូចជាពេលគោរពទង់ជាតិ ឬមុនពេលចេញទៅផ្ទះវិញ
- ដាក់ជាវិញ្ញាសាប្រឡងប្រចាំខែ ប្រចាំឆមាស ស្របតាមស្ថានភាពជាក់ស្ដែង
- ក្ដាប់ព័ត៌មាន និងរាយការណ៍ជូនសមត្ថកិច្ច នូវរាល់បទល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀនខុសច្បាប់ នៅតាមគ្រឹះស្ថានសិក្សា



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- រាយការណ៍ពីលទ្ធផលការងារនេះ មកក្រសួង (នាយកដ្ឋានសុខភាពសិក្សា) នៅរៀងរាល់សប្តាហ៍ចុងក្រោយនៃខែនីមួយៗ ដើម្បីក្រសួងមានមូលដ្ឋានក្នុងការបូកសរុបរាយការណ៍ជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា គ្រប់រាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីអនុវត្តសេចក្តីណែនាំនេះ ឱ្យបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់កុំបីខាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**<u>ចម្លងជូន</u>**

- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ *"ដើម្បីជូនជ្រាប និងសហការ"*
- សាលារាជធានី-ខេត្ត *"ដើម្បីជូនជ្រាប"*
- មន្ទីរ អយក រាជធានី-ខេត្ត *"ដើម្បីអនុវត្ត"*
- អង្គភាពពាក់ព័ន្ធក្រោមឱវាទ *"ដើម្បីមុខការ"*
- កាលប្បវត្តិ
- ឯកសារ.នសស